**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងសុខាភិបាល**

លេខ : ៣៦៩៧ មស.សវ៨៣

**សេចក្តីជូនដំណឹង**

**ស្តីពី**

**ការចាក់វ៉ាក់សាំងកូវីដ-១៩ (ស៊ីណូវ៉ាក់) ជូនសមាជិកគ្រួសារអាយុចាប់ពី ០៦ឆ្នាំ ដល់ អាយុក្រោម១២ឆ្នាំ របស់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការ នៃក្រសួងសុខាភិបាល**

យោងសេចក្តីជូនព័ត៌មានលេខ៨៤៩/២១គ.វ.ក-១៩ ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០២១ របស់គណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខណ្ឌទូទាំងប្រទេស ស្តីពី ការចាក់វ៉ាក់សាំងកូវីដ-១៩ (ស៊ីណូវ៉ាក់) ដូសទី១ និងដូសទី២ ជូនដល់កុមារដែលមានអាយុចាប់ពី ៦ឆ្នាំ ដល់អាយុក្រោម ១២ឆ្នាំ តំណាងឱ្យអនុគណៈកម្មការចាក់វ៉ាក់សាំងកូវីដ-១៩ របស់ក្រសួងសុខាភិបាល ខ្ញុំសូមគោរពជម្រាបជូនដំណឹងដល់ **ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាថ្នាក់ដឹកនាំ មន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យា** ថ្នាក់ជាតិទាំងអស់មេត្តាជ្រាបថា ការចាក់វ៉ាក់សាំងកូវីដ-១៩ ជូនដល់កុមារដែលមានអាយុចាប់ពី ៦ឆ្នាំ ដល់អាយុក្រោម ១២ឆ្នាំ ដែលជាសមាជិកគ្រួសាររបស់ **ឯកឧត្តម លោកជំទាវ លោក លោកស្រី** នឹងប្រព្រឹត្តទៅ**ចាប់ពីម៉ោង ០៨:០០នាទី ដល់ម៉ោង១១:០០នាទីព្រឹក និងចាប់ពីម៉ោង១៤:០០នាទី ដល់ម៉ោង ១៧:០០នាទី** ទៅតាមថ្ងៃខែឆ្នាំ និងទីកន្លែងកំណត់ដូចខាងក្រោម៖

**១. ចាប់ពីថ្ងៃទី២៩ ដល់ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២១**

- **មន្ទីរពេទ្យកាល់ម៉ែត** សម្រាប់ចាក់ជូនសមាជិកគ្រួសារឥស្សរជនដែលមានតួនាទីជារដ្ឋមន្ត្រី រដ្ឋលេខាធិការ ឬមានឋានៈស្មើ
- **មន្ទីរពេទ្យព្រះអង្គឌួង** សម្រាប់ចាក់ជូនសមាជិកគ្រួសារឥស្សរជនដែលមានតួនាទីជាអនុរដ្ឋលេខាធិការ អគ្គនាយក អគ្គនាយករង ឬមានឋានៈស្មើ

**២. ចាប់ពីថ្ងៃទី០៣ ដល់ថ្ងៃទី០៥ ខែតុលា ឆ្នាំ២០២១**

**មន្ទីរពេទ្យកុមារជាតិ** សម្រាប់ចាក់សមាជិកគ្រួសារមន្ត្រីរាជការចាប់ពីថ្នាក់ប្រធាននាយកដ្ឋានចុះ និងមន្ត្រីជាប់កិច្ចសន្យា

ដើម្បីជួយឲ្យកិច្ចការនេះប្រព្រឹត្តទៅដោយរលូន សូម **ឯកឧត្តម លោកជំទាវ លោក លោកស្រី** សហការចូលរួមដូចខាងក្រោម៖

ក. ផ្តល់ឈ្មោះ និងអាយុសមាជិកគ្រួសារដែលមានអាយុចាប់ពី ៦ឆ្នាំ ដល់អាយុក្រោម ១២ឆ្នាំ ទៅអគ្គនាយកដ្ឋាន អគ្គាធិការដ្ឋាន និងអង្គភាពថ្នាក់ស្មើទាំងអស់របស់ **ឯកឧត្តម លោកជំទាវ លោក លោកស្រី** ដើម្បីអង្គភាពបូកសរុប និងផ្តល់ព័ត៌មានទៅ**នាយកដ្ឋានគ្រប់គ្រងបុគ្គលិកឲ្យបានមុនថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០២១។**

ខ. យកជាមួយទៅកន្លែងចាក់វ៉ាក់សាំងនូវឯកសារបញ្ជាក់ពីភាពជាសមាជិកគ្រួសាររបស់ **ឯកឧត្តម លោកជំទាវ លោក លោកស្រី** នៃអ្នកដែលត្រូវចាក់វ៉ាក់សាំង ដូចជា សំបុត្រកំណើត ឬសៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅ ឬលិខិតឆ្លងដែន និងប័ណ្ណសម្គាល់ខ្លួនមន្ត្រីរាជការ ឬប័ណ្ណសម្គាល់មន្ត្រីជាប់កិច្ចសន្យារបស់ **ឯកឧត្តម លោកជំទាវ លោក លោកស្រី។**

សម្រាប់សមាជិកគ្រួសារមន្ត្រី និងមន្ត្រីជាប់កិច្ចសន្យានៃមន្ទីរសុខាភិបាលរាជធានី ខេត្តទាំងអស់ សូមអនុវត្តតាមការរៀបចំរបស់រដ្ឋបាលរាជធានី ខេត្តទាំង២៥។

អាស្រ័យហេតុនេះ សូម **ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាមាតាបិតា និងអាណាព្យាបាល** មេត្តានាំសមាជិកគ្រួសារដែលមានអាយុចាប់ពី ៦ឆ្នាំ ដល់អាយុក្រោម ១២ឆ្នាំ ទៅចាក់វ៉ាក់សាំងកូវីដ-១៩ ដូចបានកំណត់ខាងលើឱ្យបានគ្រប់គ្នា។

ថ្ងៃច័ន្ទ ១៤ កើត ខែភទ្របទ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ២០២១

**រដ្ឋលេខាធិការ និងជាប្រធានអនុគណៈកម្មការ**

**ចាក់វ៉ាក់សាំងកូវីដ-១៩របស់ក្រសួងសុខាភិបាល**

ក្រសួងសុខាភិបាល

**អេង ហ៊ុនឆលី**

ផ្លូវវិថីអង្គតាមិញ ភូមិគោកចំបក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ/ទូរសារ : +៨៥៥-២៣-៨៦៦៥០១/+៨៥៥-២៣-៨៦៦៥០៥ | គេហទំព័រ : http://www.mcs.gov.kh